ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៥៤៤

ចុះថ្ងៃទី ២៧-៦-២០១១

សាលដីកា

លេខ: ៩៦ "ក្រ ប ស"

ចុះថ្ងៃទី ១១-៩-២០១២

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍

បង្កើតឡើង តាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ២៨-៨-២០១២ ដែលមានសមាសភាពដូចខាងក្រោម ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធាន |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |

## តំណាងមហាអយ្យការ

| | | |
|---|---|---|
| លោក | [redacted] | ព្រះរាជអាជ្ញា |

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៥៤៤ ចុះថ្ងៃទី ២៧-៦-២០១១ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] សំអាត ហៅ នួន វិរៈ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរ កងយោធពលរខេមរភូមិន្ទ ទីកន្លែងកំណើតនៅភូមិពាមក្នុង ឃុំពាមកោះស្លា ស្រុកស្ទឹងត្រែង ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្នភូមិ២ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី ០៥-០២-២០១០ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំ ខ្លួនលេខ: ១៩៩ ត.ព្រ ចុះថ្ងៃទី ០៩-០២-២០១០ នៅពន្ធនាគារ ម១ ព្រៃស ។

-មេធាវីការពារជនជាប់ចោទលោក [redacted] វុទ្ធា

២-ជនជាប់ចោទឈ្មោះ [redacted] ទិត្យ ហៅ ស្មី ហៅ ម៉ាប់ ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ កងយោធពលរខេមរភូមិន្ទ ទីកន្លែងកំណើតនៅភូមិខ្សាម ឃុំកំពង់ឆ្នាំង ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង មានទីលំនៅបច្ចុប្បន្នភូមិអូរបារាខាងកើត [redacted] ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ: ៧១៣ ត.ព្រ ចុះថ្ងៃទី ១៧-៩-២០០៩ ។

<u>ជាប់ចោទពីបទ:</u> ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តិនៅចំណុចមុខវត្តបុទុមវត្តី ផ្លូវលេខ ៧ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃ ០៥-០២-២០១០ បទល្មើសព្រហ្មទណ្ឌ



Scanned with CamScanner

ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ៦រឿងហេតុមានដូចតទៅ

**សកម្មភាព** ប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ៖

ឈ្មោះ [redacted] សំអាត ហៅ នួន វិរៈ ថាគ្រឿងញៀន ដែលសមត្ថកិច្ចដកហូតបាននោះ គឺពិតជារបស់ខ្លួន ដែលទទួលពីឈ្មោះ ស្មី ហៅ ម៉ាប់ ឲ្យខ្លួនទុកប្រគល់ឲ្យម៉ូយ កាលពីថ្ងៃទី ៣០-០១-២០១០ ខ្លួនត្រូវបានឈ្មោះ អារុន ទទួលបញ្ជាពីឈ្មោះ ស្មី ហៅ ម៉ាប់ មកទទួលឌុបពីចំណតរថយន្តវត្តទេពប្រណម្យជិតផ្សារឧត្តុងមកភ្នំពេញ ដើម្បីឲ្យជួយធ្វើការរំលោះលុយដែលជំពាក់។ រហូតមកដល់ថ្ងៃទី ០៤-០២-២០១០ ឈ្មោះ ស្មី ហៅ ម៉ាប់ បានឲ្យឈ្មោះ [redacted]សំអាត ឡើងជិះរថយន្តជាមួយសំដៅមកវិមានឯករាជ្យ ពេលមកដល់វិមានឯករាជ្យឈ្មោះ ម៉ាប់ បានឲ្យឈ្មោះ [redacted] សំអាត ចុះពីរថយន្តរួចហុចកញ្ចប់ថ្នាំញៀនមកឲ្យឈ្មោះ នុត សំអាត ទុកប្រគល់ឲ្យម៉ូយ។ បន្ទាប់មកឈ្មោះ [redacted]សំអាត បានដូរគោលដៅពីវិមានឯករាជ្យមកមុខវត្តបុទុមវត្តីវិញ តាមបញ្ជារបស់ឈ្មោះ ស្មី ហៅ ម៉ាប់ រហូតដល់ម៉ោង ១៥ និង ៣០នាទី ថ្ងៃដដែលក៏ឃើញរថយន្តម៉ូយមកដល់ ពេលកំពុងប្រគល់កញ្ចប់ថ្នាំញៀន ឲ្យម៉ូយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

**បានឃើញ** សាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខៈ ៣៣ "ក.ប.៤" ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១១ សម្រេចថាៈ

១-ផ្តន្ទាទោសជនជាប់ចោទៈ

ក-ឈ្មោះ [redacted] សំអាត ហៅ នួន វិរៈ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៧ឆ្នាំ (ប្រាំពីរឆ្នាំ) និងពិន័យជាប្រាក់ចំនួន ១៥.០០០.០០០រ (ដប់ប្រាំលានរៀល) សំរាប់ដាក់ចូលថវិការដ្ឋ ។

ខ-ឈ្មោះ [redacted]ទិត្យ ហៅ ស្មី ហៅ ម៉ាប់ ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគាររយៈពេល ០៧ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១៥.០០០.០០០រ (ដប់ប្រាំលានរៀល) សំរាប់ដាក់ចូលថវិការដ្ឋ។

<u>ពីបទៈ</u> ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចមុខវត្តបុទុមវត្តី ផ្លូវលេខ៧ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៥-០២-២០១០ តាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុដែលចាប់យកមានៈ គ្រឿងញៀនថ្នាំគ្រាប់ Methamphetamine "WY" ១០កញ្ចប់ពណ៌ខៀវ ចំនួន ១៩៦៦ គ្រាប់ ស្ថិតក្នុងស្រោមសំបុត្របិទជិត សម្រេចរឹបអូស និងបំផ្លាញចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៣-០២-២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំអាត មេធាវីការពារសិទ្ធិជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ទិត្យ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១០-០៣-២០១១ ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ២១២ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១១ របស់មេធាវី [redacted] វុទ្ធា (ទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីឈ្មោះ [redacted] សំអាត ) ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៣៣ "ក.ប.៤" ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១០ គ្រង់សេចក្តីសម្រេចទាំងមូល ។

**បានឃើញ**របាយការណ៍សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៤៤ ចុះថ្ងៃទី ២៧-៦-២០១១ របស់ចៅក្រមរបាយការណ៍ នៃសាលាឧទ្ធរណ៍ ។



Scanned with CamScanner

**បានឃើញ**សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿងក្តី ។

-ជនជាប់ចោទឈ្មោះ [redacted] សំអាត (វត្តមាន)

-មេធាវីការពារជនជាប់ចោទលោក [redacted] វុទ្ធា (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] សំអាត បានឆ្លើយថាៈ ខ្ញុំបានទទួលបញ្ញើពីគេទេ ដោយមិនដឹងថាក្នុងនោះមានថ្នាំញៀនទេ ក្នុងការប្រគល់ឲ្យនោះមានឈ្មោះ [redacted] ហៅ ស្មី ប្រគល់នៅបេនឡានដោយទុក ឲ្យបងប្អូនរបស់គេ តាមលេខទូរស័ព្ទ យកទៅឲ្យនៅវត្តបទុមវត្តី ថងនោះពណ៌ខ្មៅ គេប្រាប់ថាជាថ្នាំក្រពះ និងថ្នាំគ្រុនពោះវៀន។ ខ្ញុំស្គាល់ឈ្មោះ ម៉ាប់ ហៅ ស្មី នោះដោយជាវបាយថ្ងៃត្រង់ខ្ញុំនៅជិតផ្សារសូរិយា ដោយគេធ្វើឲ្យផង ព្រោះគេ ប្រញាប់ទៅខេត្ត។ ម្យ៉ាងទៀតសមត្ថកិច្ច បានសំឡុតខ្ញុំឲ្យឆ្លើយ និងធ្វើបានខ្ញុំ។

(ក្រឡាបញ្ជីអានអំណានលទ្ធផលកោសលវិច័យ)

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ធ្វើឡើងត្រឹមត្រូវតាមមាត្រា ៣៨២ ។ មានភស្តុតាង និងសំអាងហេតុត្រឹមត្រូវសំរាប់ដាក់បន្ទុកដល់ជនជាប់ចោទ ក៏ដូចជាចម្លើយសារភាពនៅនគរបាល នឹងវត្ថុតាងគ្រប់គ្រាន់ ដូចនេះសូមតម្កល់សាលក្រមសាលាដំបូងទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-មេធាវីការពារលោក [redacted] វុទ្ធា ធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្ញុំ បានទទួលកញ្ចប់មួយ ពីឈ្មោះ ម៉ាប់ ហៅ ស្មី (ពេលបាយនៅជិតផ្សារសូរិយា) ដែលគាត់បានទទួលបញ្ញើពីគេ ម្យ៉ាងទៀតសមត្ថកិច្ចមិនទាន់ចាប់បានអ្នកផ្ញើនៅឡើយ ដើម្បីបញ្ជាក់ឲ្យពិតប្រាកដ នឹងគាត់មិនមានចេតនាប្រព្រឹត្ត ដូចនេះ សូមប្រធានក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោស ដល់គាត់ផង ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ២១២ ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] វុទ្ធា ជាមេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីជនជាប់ចោទឈ្មោះ [redacted] សំអាត ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ ។

២-កាលពីឆ្នាំ ០៥-០២-២០១០ ម៉ោងប្រហែល ៣ និង៣០នាទី រសៀល នៅចំណុចមុខវត្តបុទុមវត្តី សង្កាត់ចតុមុខមានអំពើជួញដូរគ្រឿងញៀន ដែលមានជនជាប់ចោទឈ្មោះ [redacted] សំអាត ហៅ នួន វិរៈ និងឈ្មោះ [redacted] ទិត្យ ហៅ ស្មី ហៅ ម៉ាប់ ដែលសមត្ថកិច្ចបង្ក្រាប ហើយចាប់ដកហូតថ្នាំញៀនប្រភេទមេតំហ្វេតាមីនសញ្ញា(WY) ចំនួន ១៩៦៦គ្រាប់ ស្មើទម្ងន់ ១៧៧ក្រាម ដែលមានបរិមាណជាតុ



Scanned with CamScanner

សុទ្ធស្មើ ១៧% ស្មើ ៣០,០៩ ក្រាម។ ពេលសមត្ថកិច្ចធ្វើការឃាត់ខ្លួន មានតែជនជាប់ចោទឈ្មោះ [redacted] សំអាត ម្នាក់ទេ។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សំអាត នាពេលសវនាការ ថាខ្លួនគ្រាន់តែទទួលបញ្ញើរបស់ឈ្មោះ [redacted]ទិត្យ ហៅ ស្មី ហៅ ម៉ាប់ ដើម្បីយកឥវ៉ាន់នោះឲ្យគេតែប៉ុណ្ណោះ មិនបានដឹងថាឥវ៉ាន់នោះជាថ្នាំញៀននោះទេ ព្រោះឈ្មោះ ស្មី បានប្រាប់ថាជាថ្នាំក្រពះ និងថ្នាំគ្រុនពោះវៀន ការឆ្លើយដោះសារនេះពុំមានមូលដ្ឋានណា ដែលអាចឲ្យ តុលាការជឿបានឡើយ ។

៤-មានពិរុទ្ធភាពគ្រប់គ្រាន់ លើជនជាប់ចោទឈ្មោះ [redacted]សំអាត ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ ដូចការចោទប្រកាន់។

៥-តុលាការសាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុ បញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់សរសេរសំអាងហេតុដដែលនោះបញ្ជាក់សារជាថ្មីទៀតទេ។

សេចក្តីសម្រេចនៃសាលក្រមលេខៈ ៣៣ កប៤ ចុះថ្ងៃទី ១០-០៣-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខៈ ២១២ ចុះថ្ងៃទី ២២-០៣-២០១១ របស់ឈ្មោះ [redacted] វុទ្ធា ជាមេធាវីទទួលសិទ្ធិពីជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៣៣ កប៤ ចុះថ្ងៃទី ១០-០៣-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]សំអាត តាមនីតិវិធី។

-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ២៨-៨-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១១-៩-២០១២ ដោយសម្រេចសេចក្តី ៖

-ចំពោះមុខជនជាប់ចោទ

-បើកសិទ្ធិប្តឹងសាទុក្ខ តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner